ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
លេខ ..០៩៨...ស.ជ.ណ

# សេចក្តីជូនដំណឹង
# ស្តីពី ការបែងចែកភាគលាភ ប្រចាំឆ្នាំ២០២០
# របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) សូមជម្រាបជូនភាគហ៊ុនិកជ្រាបថា រ.ទ.ស.ភ នឹងធ្វើការបែងចែកភាគលាភជូនភាគហ៊ុនិកកាន់កាប់ភាគហ៊ុនធម្មតា ដូចខាងក្រោម៖

- ប្រភេទនៃភាគលាភដែលត្រូវបែងចែក: សាច់ប្រាក់
- ប្រភពនៃភាគលាភ: ប្រាក់ចំណេញប្រចាំឆ្នាំ២០២០
- ចំនួនដងនៃការបែងចែកភាគលាភ: ប្រចាំឆ្នាំ
- អនុបាតនៃការបែងចែកភាគលាភ: ២៥,៧៩%
- ភាគលាភសរុបដែលត្រូវបែងចែក: ២២.៧៨៦.៩៦៨.៤៤៤ រៀល
- ភាគលាភក្នុងមួយភាគហ៊ុន: **២៦២ រៀល**
- កាលបរិច្ឆេទអិចឌីវីដិនដ៍ (Ex-Dividend) ឬអិចរាយថ៍ (Ex-Right): ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១
- កាលបរិច្ឆេទកំណត់ទុកនៃការបែងចែកភាគលាភ: ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២១
- កាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ: ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១
- ប្រាក់ចំណេញដែលនៅសល់ពីការបែងចែកភាគលាភខាងលើ ត្រូវរក្សាទុកសម្រាប់ការវិនិយោគរបស់ រ.ទ.ស.ភ នាពេលខាងមុខ ដែលមានចំនួនសរុប ៥៦.៧២៩.៦៩២.០៥៦រៀល។

**បញ្ជាក់**

១- ភាគហ៊ុនិកមានសិទ្ធិទទួលបានភាគលាភដូចបានកំណត់ខាងលើនេះ ជាភាគហ៊ុនិកដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះផ្លូវការ ដោយទទួលបានពីបញ្ជីឈ្មោះភាគហ៊ុនិកដែលរៀបចំឡើង នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១។

២- ភាគហ៊ុនិកដែល**លក់**ភាគហ៊ុនធម្មតារបស់ រ.ទ.ស.ភ នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ **នៅតែមានសិទ្ធិទទួលបានភាគលាភ** ដូចបានកំណត់ខាងលើ។

៣- ភាគហ៊ុនិកដែល**ទិញ**ភាគហ៊ុនធម្មតារបស់ រ.ទ.ស.ភ នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ **មិនមានសិទ្ធិទទួលបានភាគលាភ** ដូចបានកំណត់ខាងលើនោះទេ។

ព័ត៌មានបន្ថែម សូមទាក់ទងទៅកាន់ **ធនាគារ អេស៊ីលីដា ភីអិលស៊ី** (ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់) តាមអាសយដ្ឋាន និងបុគ្គលទំនាក់ទំនងដូចខាងក្រោម៖


អគារ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ:(៨៥៥) ២៣ ៦៣៥ ៨០ ៨០ Email: admin@ppwsa.com.kh

**អាសយដ្ឋាន:** អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

- **លោក លឹម អាន** ប្រធានផ្នែកជាន់ខ្ពស់ប្រតិបត្តិការ RTP
  ទូរស័ព្ទ: (៨៥៥)១៥ ៦០០ ៧៤៣ / ៧៧ ៥៦៧ ៩៣៥ (បន្តទៅលេខ 05013)
  អ៊ីម៉ែល: lim.an@acledabank.com.kh
  lim.phengan@gmail.com
- **លោក ហួត សុភី** អនុប្រធានផ្នែកប្រតិបត្តិការ RTP
  ទូរស័ព្ទ: (៨៥៥)១៥ ៩០០ ៥៣៨ (បន្តទៅលេខ 05020)
  អ៊ីម៉ែល: huot.sophy@acledabank.com.kh
- **លោកស្រី សំរិទ្ធ វណ្ណីបុប្ផារង្ស** បុគ្គលិកផ្នែកប្រតិបត្តិការ RTP
  ទូរស័ព្ទ: (៨៥៥)៨១ ៦៨៦ ៩៨៨ / ៦១ ២៨៧ ៧៦៦ (បន្តទៅលេខ 05020)
  អ៊ីម៉ែល: op.rtp@acledabank.com.kh

ថ្ងៃសុក្រ ១០កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

**<u>ចម្លងជូន៖</u>**
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- និយ័តករមូលបត្រកម្ពុជា
- ឯកឧត្តមប្រធាន និងគ្រប់សមាជិកក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ
- មន្ត្រីត្រួតពិនិត្យរដ្ឋអម រ.ទ.ស.ភ

"*មេត្តាជ្រាប*"

- ឯកសារ-កាលប្បវត្តិ



អគារ ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទៈ (៨៥៥) ២៣ ៦៣៥ ៨០ ៨០ Email: admin@ppwsa.com.kh